**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ 03.026/07 គ.ជ.ប/អគ្គ

# ជម្រាបមក

**លោក ប្រធានគណៈកម្មការរៀបចំការបោះឆ្នោត ក្រុងភ្នំពេញ**

**កម្មវត្ថុ** : ជួយជម្រាបទៅគ្រប់ការិយាល័យបោះឆ្នោត ទូទាំងក្រុងភ្នំពេញ ឱ្យជួយសម្រួល និងផ្តល់អាទិភាពដល់ មន្ត្រីព័ត៌មាន ទូរទស្សន៍ជាតិកម្ពុជា បានចូលបោះឆ្នោតមុនគេ ក្នុងថ្ងៃបោះឆ្នោត

**យោង** : -បទបញ្ជា និងនីតិវិធី គ.ជ.ប ជំពូកទី ១០ ចំនុច ១០.៦.៨
-លិខិតលេខ ៦៨/០៧ ទទក ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៧ របស់ឯកឧត្តម អគ្គនាយកទូរទស្សន៍ ជាតិកម្ពុជា

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ អគ្គលេខាធិការ គ.ជ.ប សូមជម្រាបលោក ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតក្រុងភ្នំពេញ ជ្រាបថា នៅថ្ងៃ អាទិត្យទី ០១ ខែ មេសា ឆ្នាំ ២០០៧ ជាថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ។ ដើម្បីជួយសម្រួលដល់មន្ត្រីព័ត៌មាន ទូរទស្សន៍ជាតិកម្ពុជា សូមលោកប្រធានជម្រាបជូនទៅគ្រប់ការិយាល័យបោះឆ្នោតទាំងអស់នៅក្នុងក្រុងភ្នំពេញ ឱ្យផ្តល់អាទិភាពដល់មន្ត្រីព័ត៌មាន របស់ទូរទស្សន៍ជាតិកម្ពុជា បានចូលបោះឆ្នោតមុនគេក្នុងថ្ងៃបោះឆ្នោត ដោយមន្ត្រីព័ត៌មានទាំងនោះ មានភារកិច្ចត្រូវចុះយកព័ត៌មាន អំពីសកម្មភាពទៅបោះឆ្នោតរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ក៏ដូចជាសកម្មភាពទៅបោះឆ្នោតរបស់ប្រជាពលរដ្ឋ នៅតាមបណ្តាខេត្ត ក្រុងនានា ក្នុងថ្ងៃបោះឆ្នោត ។

មន្ត្រីព័ត៌មានទូរទស្សន៍ជាតិកម្ពុជា ដែលអនុញ្ញាតឱ្យបោះឆ្នោតមុនគេ គឺមន្ត្រីដែលមាន ៖

- ប័ណ្ណសំគាល់ខ្លួន របស់ទូរទស្សន៍ជាតិកម្ពុជា
- ប័ណ្ណអ្នកសារព័ត៌មានជាតិ ចេញដោយ គ.ជ.ប
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ

អាស្រ័យហេតុនេះ សូមលោកប្រធាន ជួយសម្រួលការងារនេះ ឱ្យមានប្រសិទ្ធភាពល្អ ។

សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី 16 ខែ មីនា ឆ្នាំ ២០០៧

**អគ្គលេខាធិការ**

ទេព នីថា

**ចំលងជូន**
-ទូរទស្សន៍ជាតិកម្ពុជា
-ឯកសារកាលប្បវត្តិ